ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១៧៥៣ ស.ស.ណ

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការផ្គត់ផ្គង់សម្ភារការិយាល័យ សម្ភារបរិក្ខារ និងគ្រឿងសង្ហារឹម សម្រាប់ឆ្នាំ២០១៦

ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស ( គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា អោយបានជ្រាបថាក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ នឹងដាក់អោយដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់សម្ភារការិយាល័យ សម្ភារបរិក្ខារ និងគ្រឿងសង្ហារឹម សម្រាប់ឆ្នាំ២០១៦ ។

ក្រសួងមហាផ្ទៃ បានរៀបចំឯកសារសម្រាប់សម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម ផ្នែករដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងហាផ្ទៃ ដែលមានអាសយដ្ឋានក្នុងទីស្តីការក្រសួងមហាផ្ទៃ ចាប់ពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ តទៅរៀងរាល់ម៉ោងធ្វើការ (ឬទាក់ទងតាមទូរស័ព្ទលេខ ០២៣ ៧២៦ ០៤៥) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅវេលាម៉ោង១០:៣០ ថ្ងៃទី១៩ ខែ៦៧ ឆ្នាំ២០១៦។

ការបើកសំណើពិគ្រោះថ្លៃ នឹងប្រព្រឹត្តទៅនៅសាលប្រជុំក្រសួងមហាផ្ទៃ វេលាម៉ោង១០:៣០ ថ្ងៃទី១៩ ខែ៦៧ ឆ្នាំ២០១៦ នៅចំពោះមុខគណៈកម្មការ និងប្រធាន ឬអនុប្រធានក្រុមហ៊ុនដែលបានចូលរួមដេញថ្លៃ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ផ្នែករដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ដើម្បីទិញឯកសារនិងសាកសួព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ព័ត៌មានផ្សេងៗសូមទាក់ទង**
-ទូរស័ព្ទលេខ : ០២៣ ៧២៦ ០៤៥

<u>ចំលងជូន</u>
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ"



ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh